ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

# របាយការណ៍
## ស្ដីពី
## សភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
## (ប្រចាំត្រីមាសទី ១ ឆ្នាំ២០១៣)

### I- សភាពការណ៍រួម

ក្នុងត្រីមាសទី១ ឆ្នាំ២០១៣ ស្ថានភាពធាតុអាកាសទទួលឥទ្ធិពលពីជ្រលងសម្ពាធទាបខ្សោយ ផ្ទៃមេឃមានពពកពីតិចទៅមធ្យម ខ្យល់បក់ពីទិសអាគ្នេយ៍និងមានភ្លៀងកក់ខែតិចតួច និងខ្យល់កន្ត្រាក់នៅតាមតំបន់មួយចំនួននៃបណ្ដាខេត្ត និងរាជធានី។ មកទល់ពេលនេះការងារបង្កបង្កើនផលស្រូវប្រាំង ក្នុងនោះដំណាំស្រូវសម្រេចបាន ១៣៥,០៤% នៃផែនការដាំដុះ ៣៦៦.៧៤១ហិកតា ទន្ទឹមនឹងនេះ ការងារប្រមូលផលដំណាំស្រូវរដូវប្រាំងសម្រេចបាន ៨៨,៩៣% នៃផ្ទៃដីអនុវត្តបាន ៤៩៥.២៥៧ហិកតា។

### II- លទ្ធផលសម្រេចបានតាមបណ្ដាផ្នែក

#### ១ ផ្នែកដាំដុះ

#### ១.១ ដំណាំស្រូវរដូវប្រាំងឆ្នាំ២០១២-២០១៣

##### ១.១.១ ដំណាំស្រូវ

-ផ្ទៃដីភ្ជួររាស់សរុបចំនួន ៥៤៧.០១៦ហិកតា លើសឆ្នាំមុន ២១.៦៨១ហិកតា

-ផ្ទៃដីសាបសរុបចំនួន ៥.៤១៣ហិកតា តិចជាងឆ្នាំមុន ១.១៤៦ហិកតា

-ផ្ទៃដីសន្ទូងនិងពង្រោះសរុបចំនួន ៤៩៥.២៥៧ហិកតា ស្មើនឹង១៣៥,០៤%នៃផែនការ ៣៦៦.៧៤១ហិកតា លើសឆ្នាំមុន២៣.៤៥៤ហិកតា

-ការងារប្រមូលផលស្រូវរដូវប្រាំងមកទល់ពេលនេះសម្រេចបានលើផ្ទៃដីចំនួន ៤៤០.៤១៥ហិកតា លើសឆ្នាំមុន ១៣៥.៨១១ហិកតា ដោយទទួលបានបរិមាណផលសរុបចំនួន ១.៩០៧.៧៧២តោន លើសឆ្នាំមុន ៥៨៥.១១៤តោន និងទិន្នផលជាមធ្យមចំនួន ៤,៣៣២តោនក្នុងមួយហិកតា តិចជាងឆ្នាំមុន ២គ.ក្រ។

##### ១.១.២ ដំណាំរួមផ្សំ

**ផ្ទៃដីសម្រេចបានចំនួន ១២០.៣៥១ហិកតា ស្មើនឹង ២៨២,៥៥ភាគរយ នៃផែនការសរុប ៤២.៥៩៥ហិកតា លើសឆ្នាំមុន ៥៥.៨៤៨ហិកតា ក្នុងនោះមាន÷**

-ផ្ទៃដីដាំពោតចំនួន ៤២.៧២១ហិកតា លើសឆ្នាំមុន ២៤.៩៧២ហិកតា ក្នុងនោះផ្ទៃដីដាំពោតក្រហមមាន ១៧.៣២១ហិកតា លើសឆ្នាំមុន ៦.០៩៥ហិកតា

-ផ្ទៃដីដំឡូងឈើចំនួន ៣០.៦២៧ហិកតា លើសឆ្នាំមុន ២៤.៣១៧ហិកតា



អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
No. 200 Preah Norodom Blvd. Sangkat Tonle Basak, Khan Chamkarmon Phnom Penh, Cambodia
ទូរស័ព្ទលេខ : (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 726 128 / 726 129 Fax : (855) 23 217 320

-ផ្ទៃដីដំឡូងជ្វាចំនួន ៣.៣៧១ហិកតា លើសឆ្នាំមុន ៣៧៩ហិកតា

-ផ្ទៃដីបន្លែគ្រប់មុខចំនួន ២៦.៥៤៨ហិកតា លើសឆ្នាំមុន ៣.៥៧៩ហិកតា

-ផ្ទៃដីសណ្ដែកបាយចំនួន ១៧.០៨៤ហិកតា លើសឆ្នាំមុន ២.៦០១ហិកតា ។

១.១.៣ ដំណាំឧស្សាហកម្ម

ផ្ទៃដីសម្រេចបាន ១៨.១៩២ហិកតា ស្មើនឹង ៩០,៧៦ភាគរយ នៃផែនការសរុប ២០.០៤៤ហិកតា លើសឆ្នាំមុន ៣.៣១៨ហិកតា ក្នុងនោះមាន÷

-ផ្ទៃដីសណ្ដែកដីចំនួន ២.៦២២ហិកតា តិចជាងឆ្នាំមុន ២៣២ហិកតា

-ផ្ទៃដីសណ្ដែកសៀងចំនួន ២.៥៩៥ហិកតា លើសឆ្នាំមុន ២.៥៨០ហិកតា

-ផ្ទៃដីល្ងចំនួន ២.២៩២ហិកតា លើសឆ្នាំមុន ១.១១៤ហិកតា

-ផ្ទៃដីអំពៅចំនួន ៣.៨៨៥ហិកតា លើសឆ្នាំមុន ១.២៩៩ហិកតា

-ផ្ទៃដីក្រចៅចំនួន ៤០ហិកតា លើសឆ្នាំមុន ៤០ហិកតា

-ផ្ទៃដីថ្នាំជក់ចំនួន ៦.៧៥៨ហិកតា តិចជាងឆ្នាំមុន ១.៤៨៣ហិកតា។

## ២ ផ្នែកព្រៃឈើ

### ២.១ ការងារចំណូលព្រៃឈើ

-ចំណូលពីផលព្រៃឈើចូលថវិកាជាតិ សរុបចំនួន៩.៦១០.១៦៦.៧៣៧រៀល ដែលក្នុងនោះបានមកពីចំណូលថ្លៃសួយសារផល អនុផលព្រៃឈើចំនួន៧.៧៨៤.២០១.៩១៦រៀល និងចំណូលបានពីការផាកពិន័យឈើដែលបានមកពីការបង្ក្រាបបទល្មើសចំនួន១.៨២៥.៩៦៤.៨២១រៀល។

### ២.២ ការងារព្រៃឈើនិងសហគមន៍ព្រៃឈើ

-ផ្ញើសារពើភ័ណ្ឌវាយតម្លៃប៉ាន់ស្មានធនធានព្រៃឈើជូនក្រុមហ៊ុនចំនួន០៧

-ផ្ដល់លិខិតបើកផ្លូវដឹកជញ្ជូនផល អនុផលព្រៃឈើ(LP) ចេញពីគម្រោងវារីអគ្គិសនីជូនក្រុមហ៊ុន អិម ឌី អេស វារីអគ្គិសនីស្ទឹងអាតៃ ខេត្តពោធិ៍សាត់ សរុបចំនួន ៣.៦៨៩,៥៨១ម៣ កូនឈើចំនួន ២៩.០០០ដើម

-ផ្ដល់លិខិតបើកផ្លូវដឹកជញ្ជូនផល អនុផលព្រៃឈើ(LP)ចេញពីព្រៃគុបផ្ដល់ផលក្រៅពីព្រៃសម្បទាន÷ ឈើហ៊ុបមូលសរុបចំនួន ៥០.៤៤៩,៩១៩ម៣ ឈើអារចំនួន ១៧៦,៨៩២ម៣ ឈើជ្រុងចំនួន ៤.៩៦៥,៨៣៤ម៣ កូនឈើចំនួន ៣៣២.១៦៦ ដើម និងអុសចំនួន ១០៤.០៣៤ស្ទែរ

-ផ្ដល់លិខិតបើកផ្លូវដឹកជញ្ជូនផល អនុផលព្រៃឈើ(LP)ទៅកាន់ទិសដៅប្រើប្រាស់របស់អតិថិជនមាន÷ ជ័រទឹកចំនួន២៨៩,៣៥២តោន។

### ២.៣ ការងារអភិរក្សសត្វព្រៃ

-គម្រោងអភិរក្សសត្វក្រៀលនិងសត្វស្លាបផ្សេងទៀតនៅតំបន់បឹងព្រែកល្ពៅ ខេត្តតាកែវ និងតំបន់អន្លង់ព្រីង ខេត្តកំពត

-គម្រោងអភិរក្សសត្វក្រៀលនៅតំបន់អាងត្រពាំងថ្ម ស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ

-គម្រោងគ្រប់គ្រងនិងអភិរក្សសត្វខ្សឹប និងជីវចម្រុះនៃប្រព័ន្ធអេកូឡូស៊ីរួមក្នុងភូមិសាស្ត្រខេត្តកំពង់ធំនិងខេត្តសៀមរាប

-គម្រោងអភិរក្សសត្វដំរីនៅកម្ពុជា

-គម្រោងអភិរក្សក្រពើភ្នំនៅកម្ពុជា

-កម្មវិធីអភិរក្សតំបន់ព្រៃការពារជួរភ្នំក្រវាញភាគកណ្ដាល

-គម្រោងអភិរក្សសម្បុកសត្វស្លាប

-គម្រោងតំបន់ព្រៃការពារព្រះវិហារ

-គម្រោងអភិរក្សសត្វស្លាបសំខាន់ៗក្នុងស្រុកសៀមប៉ាង

-គម្រោងអភិរក្សជីវចម្រុះវើនសៃ សៀមប៉ាង

-គម្រោងព្រៃការពារអូរយ៉ាដាវ ខេត្តរតនគីរី

-គម្រោងគ្រប់គ្រងព្រៃការពារមណ្ឌលគីរី

-គម្រោងអភិរក្សជីវចម្រុះតំបន់ត្រីកោណមរកតថៃ-កម្ពុជា-ឡាវ

-ការងារនៅឧទ្យានសួនសត្វនិងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅកំពុងចិញ្ចឹម និងថែរក្សាសរុបចាប់ពីដើមឆ្នាំ សត្វចំណូលថ្មីចំនួន១២២ក្បាល សត្វកើតថ្មីចំនួន០៨ក្បាល សត្វដោះលែងចំនួន៨៨ក្បាល សត្វស្លាប់ចំនួន៣០ក្បាល ព្យាបាលសត្វចំនួន៧៩ក្បាល យកសំណាកទៅពិសោធន៍ចំនួន២២ក្បាល ធ្វើឲ្យសន្លប់ចំនួន៤៩ក្បាល ទម្លាក់សត្វល្អិតចំនួន១៦៩ក្បាល វះកាត់សាកសពសត្វចំនួន១២ក្បាល ដាក់លេខកូដចំនួន០៣ក្បាល ចាក់វ៉ាក់សាំងចំនួន២០៤ក្បាល ជួសជុលផ្លូវចំនួន១០.៧២០ម² និងឆ្ការអនាម័យព្រៃ២១.៤៨៨ម² សាងសង់ទ្រុងសត្វនិងអគារផ្សេងៗចំនួន៩៩១ម² សាងសង់របងហ៊ុមព័ទ្ធនិងទ្រុងសត្វថ្មីលើដីចំនួន៩.៣៩៦ម² សាងសង់សំណង់ផ្សេងៗចំនួន៩៦០ម² ដាំកូនឈើចំនួន២០០ដើម និងអប់រំផ្សព្វផ្សាយដល់សិស្សានុសិស្សបានចំនួន២.៩៥៣នាក់

-ក្រុមហ៊ុនចំនួន ០៧ កំពុងចិញ្ចឹមស្វាក្អាមចំនួន៧៧.១២៩ក្បាល។

## ២.៤ ការងារដាំដើមឈើ

-ស្ថានីយផ្សព្វផ្សាយនិងស្តារព្រៃឈើចំនួន ០៥កន្លែងរបស់រដ្ឋបាលព្រៃឈើ បណ្តុះកូនឈើក្រញូងបានចំនួន ២៩០.០០០ដើម ឈូសឆាយដីព្រៃបានចំនួន៣០ហិកតាលើផែនការចំនួន៤០០ហិកតា និងដាំជួសចម្ការឈើចាស់បានចំនួន១០ហិកតាលើផ្ទៃដីចំនួន៣.៨៦៨ហិកតា ត្រូវធ្វើការថែទាំនិងដាំជួសជុលចម្ការឆ្នាំទី១ឬឆ្នាំទី២ ដែលទទួលរងការខូចខាតដោយភ្លើងឆេះ ត្រូវធ្វើការដាំបំពេញផែនការឡើងវិញ និងមានវិធានការទប់ស្កាត់ការបំផ្លិចបំផ្លាញ និងការកាប់រុករានចម្ការឈើដាំរបស់រដ្ឋ

-ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចចំនួន០៨÷ ឈូសឆាយដីព្រៃចំនួន ៦.៥៩៧,២២ហិកតា ដាំកូនឈើនិងកូនកៅស៊ូចំនួន ១.៣៨០,៧៨ហិកតា

-ថ្នាលបណ្តុះកូនឈើរបស់រដ្ឋបាលព្រៃឈើអនុវត្ត÷ កូនឈើសល់ស្តុកក្នុងឆ្នាំ២០១២ចំនួន៦៤៦.៧១៤ដើម កូនឈើបណ្តុះក្នុងឆ្នាំ២០១៣ចំនួន៩២.០០២ដើម និងចែកចាយកូនឈើចំនួន៧៩.២៥៥ដើម

-ជ្រើសរើសទីតាំងបង្កើតចម្ការពូជ១កន្លែងទំហំ៥ហិកតានៅខេត្តកំពង់ធំ ដើម្បីអភិវឌ្ឍធនធានសេនេទិចព្រៃឈើ

-ការដាំឈើដៃគូជាមួយក្រុមហ៊ុន Think Biotech(Cambodia) Co., Ltd បានសាង់សង់ផ្លូវចូលចំនួន១០គ.ម លើផែនការ៧០គ.ម ឈូសឆាយផ្លូវមេបានចម្ងាយ៦០គ.ម រៀបចំថ្នាលបណ្តុះទំហំ១០ហិកតា សាងសង់ជំរំការដ្ឋានរួមមានអគារស្នាក់នៅចំនួន៥ខ្នង រោងជាង០១ ការិយាល័យ០១ និងអាងស្តុកទឹក០១ ឈូសឆាយដីព្រៃចំនួន៥០ហិកតា ប្រមូលកាកសំណល់ឈើចំនួន១.៥០០ដើម

-ការដាំឈើដៃគូជាមួយក្រុមហ៊ុន អូជី (ខេមបូឌា) ផ្លេនថេសិន ហ្វរីស ខមភេនី លីមីធីត ធ្វើការកំណត់ព្រំនិងបោះបង្គោលព្រំលើផ្ទៃដីចំនួន៣០០ហិកតា នៅក្នុងអនុតំបន់១ កំពុងសាងសង់ស្នាក់ការ១កន្លែងនៅក្នុងទីតាំងស្ថានីយមានក និងបណ្តុះពូជសម្រាប់ដាំចំនួនកន្លះលានដើម។

## ២.៥ ការងារឧស្សាហកម្មនិងពាណិជ្ជកម្ម

### ២.៥.១ ការងារពាណិជ្ជកម្មនាំចេញ នាំចូល

-ពិនិត្យឯកសារស្នើសុំពាក់ព័ន្ធនឹងការនាំចេញនាំចូលចំនួន ០៦ក្រុមហ៊ុន

-ផ្តល់អាជ្ញាប័ណ្ណនាំចេញឈើគ្រប់ប្រភេទជូនក្រុមហ៊ុនចំនួន០៥ ស្មើ១០.៣៥៥,៧៦៥ម៣

-ពន្យារអាជ្ញាប័ណ្ណនាំចេញជូនក្រុមហ៊ុនចំនួន០១ ស្មើ៦១,៣៥២ម៣។

២.៥.២ ការងារឧស្សាហកម្ម

-ផ្តល់លិខិតអនុញ្ញាតដឹកជញ្ជូនផល អនុផលព្រៃឈើនាំចេញជូនក្រុមហ៊ុនចំនួន០៣ ស្មើនឹង ៤.៧៣១,៤២៣ម៣។

**២.៦ ការងារនីតិកម្មនិងវិវាទ**

-បង្ក្រាបបទល្មើសព្រៃឈើ សត្វព្រៃ និងបទល្មើសកាប់រានទន្ទ្រានដីព្រៃសរុបចំនួន ២៦៤ករណី

-ឃាត់ខ្លួនជនជាប់ចោទនិងដកហូតវត្ថុតាងមានដូចជា ឈើហ៊ុបមូលចម្រុះប្រភេទចំនួន១២៤,០២៣ម៣ ឈើអារចំនួន១.២១២,៤៧០ម៣ ឈើក្រាក់ក្រញូងចំនួន១១,៤៣០ម៣និង២១៥គ.ក្រ កូនឈើចំនួន៤៥៥ដើម ឈើជន្លង់ម្រេចចំនួន៨៩៤ដើម ឫស្សីចំនួន១២៥ដើម អុសចំនួន៣៥,៦០ស្ទេរ ធ្យូងចំនួន៦.០០០គ.ក្រ ជ័រទឹកចំនួន៥.០០០គ.ក្រ ពកផ្ទង់ចំនួន១៣០គ.ក្រ គ្រាប់ស្លែងចំនួន៥.៣៥៩គ.ក្រ សត្វព្រៃចម្រុះគ្រប់ប្រភេទចំនួន១១,២០គ.ក្រនិង២៥៦ក្បាល រថយន្តចំនួន១០៧គ្រឿង ត្រាក់ទ័រចំនួន០៤គ្រឿង ម៉ូតូចំនួន២៨គ្រឿង ទូក-កាណូតចំនួន០៧គ្រឿង គោយន្តចំនួន០១គ្រឿង ម៉ូតូកង់បីចំនួន០១គ្រឿង រទេះកង់ឡានចំនួន១១គ្រឿង រណារយន្តចំនួន២៣គ្រឿង ម៉ាស៊ីនផ្សេងៗចំនួន១៥គ្រឿង និងសម្ភារផ្សេងៗទៀត ព្រមទាំងដកហូតដីព្រៃឈើចំនួន ៥៤,៤៩ហិកតា

-ចុះស្រង់ស្ថិតិដីព្រៃឈើដែលបានកាប់រាន ដុត ឈូសឆាយ និងហ៊ុមព័ទ្ធដីព្រៃឈើ ដើម្បីរាតយកដីធ្វើកម្មសិទ្ធិចំនួន ១.៥៣៦,៦៨១ហិកតា និងដកហូតដីព្រៃដែលបានកាប់រានសរុបចំនួន៦០,៩៩១ហិកតា ។

## ៣ ផ្នែកជលផល

**៣.១ អាជីវកម្មនេសាទ**

៣.១.១ នេសាទទឹកសាប

-ដាយត្រីក្នុងរដូវនេសាទឆ្នាំ២០១២-២០១៣ សរុបបានចំនួន៨.៥០០តោន ស្មើ៨៥%នៃផែនការ១០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន៣៧.៥០០តោន

-នេសាទគ្រួសារក្នុងដែននេសាទរដូវឆ្នាំ២០១៣ សរុបបានចំនួន៧០.០០០តោន ស្មើ ២៣,៣៣% នៃផែនការ ៣០០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន៤០.០០០តោន

-នេសាទគ្រួសារតាមវាលស្រែក្នុងរដូវឆ្នាំ២០១៣ សរុបបានចំនួន២៥.០០០តោន ស្មើ ១៦,៦៧% នៃផែនការ ១៥០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន២០.០០០តោន ។

៣.១.២ នេសាទសមុទ្រក្នុងឆ្នាំ២០១៣

-សរុបបានចំនួន២៥.០០០តោន ស្មើ ២៧,៧៨% នៃផែនការ៩០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន១.០០០តោន។

**៣.២ វារីវប្បកម្ម**

-ការចិញ្ចឹមត្រីនិងបង្គា សរុបបានចំនួន១៨.០០០តោន ស្មើ២២,៥០%នៃផែនការ ៨០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន២.០០០តោន

-ការចិញ្ចឹមក្រពើ សរុបបានចំនួន២៣.០០០ក្បាល ស្មើ១១,៥០% នៃផែនការ២០០.០០០ក្បាល ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន៣.០០០តោន

-ការភ្ញាស់កូនត្រីពូជ សរុបបានចំនួន១៦.០០០.០០០កូន ស្មើ១០,៦៧% នៃផែនការ១៥០.០០០.០០០កូន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន១.០០០.០០០កូន ។

**៣.៣ ការកែច្នៃផលនេសាទ**

-ផលនេសាទទឹកសាបក្នុងរដូវនេសាទ២០១២-២០១៣ សរុបបានចំនួន១៥.០០០តោន ស្មើ១៥% នៃផែនការ ១០០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន១៥.០០០តោន

-ផលនេសាទសមុទ្រក្នុងឆ្នាំ២០១៣ សរុបបានចំនួន២.៣០០តោន ស្មើ៣៨,៣៣% នៃផែនការ៦.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន១០០តោន

-ការផលិតទឹកត្រី សរុបបានចំនួន១៦.០០០.០០០លីត្រ ស្មើ២៦,៦៧% នៃផែនការ៦០.០០០.០០០លីត្រ ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន១.០០០.០០០តោន។

**៣.៤ ការនាំចេញផលនេសាទ**

-ផលនេសាទស្រស់ សរុបបានចំនួន៣.០០០តោន ស្មើ១៥% នៃផែនការ២០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន២.៥០០តោន

-ផលនេសាទកែច្នៃ សរុបបានចំនួន១.៥០០តោន ស្មើ១៥% នៃផែនការ១០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន៥០០តោន។

**៣.៥ ការការពារប្រភពធនធានជលផល**

-កំណត់ហេតុបទល្មើស សរុបចាប់ពីដើមឆ្នាំចំនួន ៦២២ករណី ដែលកើតមាននៅតំបន់ទឹកសាប ៦០០ករណី និងតំបន់សមុទ្រ ២២ករណី ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន ៧២ករណី គឺតំបន់ទឹកសាប ៥០ករណី និងតំបន់សមុទ្រថយចុះ២២ករណី។ ជំរុញការចុះត្រួតពិនិត្យនិងមានវិធានការដើម្បីលុបបំបាត់បទល្មើសនេសាទតាមគ្រប់រូបភាព។

**៣.៦ ការប្រមូលថវិកា**

-ចំណូលពីវិស័យជលផល សរុបបានចំនួន៩៧៧.៣១១.១៩៨រៀល ស្មើ៣៣,១៦% នៃផែនការ២.៩៤៧.០០០.០០០ រៀល ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន ៤៩៨.០៣១.៣០២រៀល។

## ៤ ផ្នែកផលិតកម្មនិងបសុព្យាបាល

**៤.១ ការចាក់ថ្នាំបង្ការជំងឺឆ្លងសត្វ**

-ចាក់ថ្នាំការពារជំងឺឆ្លងលើគោ ក្របី ជំងឺសារទឹកចំនួន ១៦៤.៥៤៣ក្បាល ជំងឺអុតក្តាមចំនួន ៦.៨៤៩ក្បាល និងជំងឺបូសខ្យល់ចំនួន ២៣១ក្បាល

-ចាក់ថ្នាំការពារជំងឺឆ្លងលើសត្វជ្រូក ជំងឺសារទឹកចំនួន ១៤.០៩៥ក្បាល ជំងឺប៉េស្តចំនួន ២៩.៣២២ក្បាល ជំងឺសាល់ម៉ូណេឡូសចំនួន ១៥.៩៣៩ក្បាល ជំងឺអុតក្តាមចំនួន ៣២៨ក្បាល ជំងឺអូហ្យេស្គីចំនួន ២.៥១៣ក្បាល ជំងឺរាគកូនជ្រូកចំនួន ៥.១៤៩ក្បាល ជំងឺកញ្រ្ជឹលចំនួន ៣១៦ក្បាល ជំងឺផ្លូវដង្ហើមចំនួន ២៤២ក្បាល និងជំងឺជាតិដែកចំនួន ២.០២២ក្បាល

-ចាក់ថ្នាំការពារជំងឺឆ្លងលើបក្សី ជំងឺអុតចំនួន ៥៥.៩០៧ក្បាល ជំងឺញីវកាសចំនួន ៧៥.៨៤៤ក្បាល ជំងឺប៉េស្តទាចំនួន ១៣.៥១១ក្បាល និងជំងឺអាសន្នរោគចំនួន ៥៧.៩៥៨ក្បាល ។

**៤.២ ការងារវិទ្យាស្ថានជាតិស្រាវជ្រាវបសុព្យាបាល**

-ចុះអង្កេតស្រាវជ្រាវកន្លែងផ្ទុះជំងឺអុតក្តាម ជំងឺសារទឹក ជំងឺបូសខ្យល់ និងជំងឺប៉េស្តជ្រូក

-រៀបចំធ្វើឲ្យប្រសើរឡើងការងារតាមដានព័ត៌មានសុខភាពសត្វ

-អង្កេតស្រាវជ្រាវ តាមដានឃ្លាំមើល និងយកវត្ថុវិភាគ ស្តីពីជំងឺផ្តាសាយបក្សីនិងជំងឺទូទៅនៅរាជធានី ខេត្ត

-ផ្នែកពិនិត្យវត្ថុវិភាគសរុបចំនួន ៩.១៦៨សំណាក

-ផ្នែកសរីរវេគសាស្ត្រសរុបចំនួន ៧៥ក្បាល ។

### ៤.៣ ការអនុវត្តវិធានបសុពេទ្យ

-ទទួលទូរស័ព្ទហៅចូលសរុបចំនួន ៤៨ករណី មកពីខេត្តស្ទឹងត្រែង បាត់ដំបង កណ្ដាល តាកែវ កំពត កែប សៀមរាប កំពង់ធំ កំពង់ចាម បន្ទាយមានជ័យ ព្រៃវែង កំពង់ស្ពឺ និងរាជធានីភ្នំពេញ សាកសួរពីរោគសញ្ញា វិធានការការពារ ការធ្វើជីវសុវត្ថិភាព និងរាយការណ៍ពីបក្សីឈឺ ងាប់

-មានផ្ទុះជំងឺផ្ដាសាយបក្សីប្រភេទ H5N1 ចំនួន៦ករណី÷ ១ករណីនៅក្នុងភូមិស្នោ ឃុំស្នោ ស្រុកព្រៃកប្បាស ខេត្តតាកែវ ១ករណីនៅក្នុងភូមិព្រៃញាតិ ឃុំព្រៃញាតិ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ២ករណីនៅក្នុងភូមិក្បាលអូរ ឃុំមេសរជ្រៃ ស្រុកស្ទឹងត្រង់និងភូមិតាឡៃ ឃុំគរ ស្រុកព្រៃឈរ ខេត្តកំពង់ចាម ១ករណីនៅភូមិស្រងែ ឃុំបឹងនិមល ស្រុកឈូក ខេត្តកំពត និង១ករណីនៅក្នុងភូមិខ្នាថ្មី សង្កាត់ជ្រាវ ក្រុងសៀមរាប ខេត្តសៀមរាប

-ត្រួតពិនិត្យនិងបង្ក្រាបបទល្មើសចលនានាំដឹកជញ្ជូនសត្វនិងផលិតផលមានដើមកំណើតពីសត្វខុសច្បាប់÷ គោចំនួន ១២ក្បាល ជ្រូកចំនួន២២ក្បាល ស៊ុតចំនួន១៦.៥០០គ្រាប់ និងធ្វើការផាកពិន័យជាទឹកប្រាក់ចំនួន ៥.០០០.០០០រៀល

-ធ្វើការឃាត់ចាប់ផលិតផលខូចគុណភាពចំនួន៦លើក ស្មើនឹង ១១៥គ.ក្រ និងធ្វើការដុតកម្ទេចចោលចំនួន៣លើក

-ចុះបាញ់ថ្នាំសម្លាប់មេរោគ(TH4) នៅតាមកន្លែងចិញ្ចឹមជ្រូកចំនួន៣៥លើក មាន់ចំនួន២១៨លើក ទាចំនួន២៧លើក កន្លែងពិឃាតមាន់ចំនួន៥លើក កន្លែងលក់មាន់ចំនួន២០លើក ទ្រុងចិញ្ចឹមចំនួន១០លើក បរិវេណភូមិចំនួន ៣៤លើក សត្តឃាតដ្ឋានចំនួន២៨លើក ផ្លូវជាតិចំនួន១លើក និងផ្សេងៗចំនួន៣៧៨លើក

-ធ្វើការទប់ស្កាត់ចលនាបក្សីនិងផលិតផលបក្សីដែលនាំចូលពីប្រទេសជិតខាង ដោយបានណែនាំប្រជាពលរដ្ឋ និងអាជីវករឱ្យយល់ដឹងពីផលវិបាកដែលបណ្ដាលមកពីជំងឺផ្ដាសាយបក្សី ។

### ៤.៤ ការងារឡជីវឧស្ម័ន

-ចុះផ្សព្វផ្សាយអត្ថប្រយោជន៍ឡជីវឧស្ម័ន

-ផលិតឡជីវឧស្ម័នសរុបចំនួន ១៨៨ឡ ។

## ៥ ផ្នែកកៅស៊ូ

### ៥.១ ការងារអាជីវកម្ម ផលិតកម្មកៅស៊ូ

| ល.រ | អង្គភាព | ផ្ទៃដីអាជីវកម្ម (ហ.ត) | ផ្ទៃដីដាំដុះនិងថែទាំ ២០០២-២០១១ (ហ.ត) | ផលិតផលអនុវត្តបានដល់ខែនេះ (តោន) | បញ្ចេញលក់ដល់ខែនេះ (តោន) |
|---|---|---|---|---|---|
| *I-ចម្ការកៅស៊ូកសិឧស្សាហកម្មរដ្ឋ* | | | | | |
| ១ | វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា | ៣៦៧,៧០ | ៤១៨,៤៧ | ៧៤,៩៣ | ៥៤,០០ |
| | ***សរុប I*** | ***៣៦៧,៧០*** | ***៤១៨,៤៧*** | ***៧៤,៩៣*** | ***៥៤,០០*** |
| *II-ចម្ការកៅស៊ូកសិឧស្សាហកម្មឯកជន* | | | | | |
| ១ | ក្រុមហ៊ុន សុភក្តិនិកា អ៊ិនវេសមេន គ្រុប | ៨.២៧៣,៤៧ | ៨.៦១៩,៨៥ | ៥.៦៤៤,០៣ | ២.៦៧៤,៨០ |
| ២ | ក្រុមហ៊ុន ស៊ីហ្វ៉ាប់បើលីមីធីត(រតនគិរី) | ១.៥៣៩,៤៧ | ៩៥៤,៨៩ | ៦៥៩,០៥ | - |
| ៣ | ក្រុមហ៊ុន ចម្ការកៅស៊ូតាប៉ាវ | ៩៨៦,៣៦ | ៩៨០,៩៧ | ២៨៤,៨២ | ១៨០,៨០ |
| ៤ | ក្រុមហ៊ុន ចម្ការកៅស៊ូបឹងកេត | ១.០២៤,៨០ | ២.៨៦៧,៩៧ | ៥៨៨,៤៦ | ១២០,០០ |
| ៥ | ក្រុមហ៊ុន ចម្ការកៅស៊ូមេមត់ខូអិលធីឌី | ៣.២៩៥,៥៨ | ៤.៤៩៦,៦៥ | ១.៦៩៧,៥១ | ៦០២,៤០ |
| ៦ | ក្រុមហ៊ុន ស៊ីហ្វ៊ីសេសស៍(ស្នួល) | ១.៥៦១,៨០ | ២.៨២៤,៤១ | ១.០៧៣,៨៣ | ៦៤០,០០ |
| ៧ | ក្រុមហ៊ុន អានម៉ាឌីគ្រុប(៣មជាំង) | ២.២៤៣,២៦ | ១.១៥៧,៦៥ | ២៤៤,៣៧ | ១៤០,៦០ |

| | | | | | |
|---|---|---|---|---|---|
| ៨ | ក្រុមហ៊ុន អានម៉ាឌីគ្រុប (ចម្ការអណ្តូង) | ២.១៣៥,២៩ | ៣.៦៨៧,៥៣ | ៣៩៩,៤៤ | ១៩១,៨០ |
| ៩ | ក្រុមហ៊ុន អានម៉ាឌីគ្រុប (រមាសហែក) | - | ៦៩៦,១៧ | - | - |
| ១០ | ក្រុមហ៊ុនក្រែក (ខេមបូឌា) ខូអិលធីឌី | ២.៦៣៤,៥៥ | ២.៦១៤,៩២ | ៨៨០,៤៩ | ៥៨៣,៨០ |
| *សរុប II* | | *២៣.៦៩៤,៥៨* | *២៨.៩០១,០១* | *១១.៤៧២* | *៥.១៣៤,២០* |
| សរុប I+II | | ២៤.០៦២,២៨ | ២៩.៣១៩,៤៨ | ១១.៥៤៦,៩៣ | ៥.១៨៨,២០ |

### ៥.២ ការផ្សព្វផ្សាយនិងបណ្តុះបណ្តាល

-បើកវគ្គបណ្តុះបណ្តាលដល់កសិករស្តីពីការដាំដុះនិងថែទាំកៅស៊ូ ដោយមានកសិករចូលរួមចំនួន៣៤នាក់

-បើកវគ្គបណ្តុះបណ្តាលដល់កសិករស្តីពីបច្ចេកទេសប្រមូលផលទឹកជ័រ ដោយមានកសិករចូលរួមចំនួន១០០នាក់

-ចូលរួមវគ្គបណ្តុះបណ្តាលស្តីពី "e-precision" និងកិច្ចប្រជុំ "អំពីផលិតផលកៅស៊ូពីកៅស៊ូ" នៅប្រទេសមីយ៉ាន់ម៉ា និងទៅសិក្សានិងដកបទពិសោធន៍ផ្ទាល់នៅវិទ្យាស្ថានស្រាវជ្រាវកៅស៊ូវៀតណាម។

### ៥.៣ ការស្រាវជ្រាវអំពីការបង្កាត់ពូជ

-ត្រួតពិនិត្យការថែទាំនិងការពារគ្រប់ឡូត៍ពិសោធន៍កូន

-រៀបចំប្រតិទិនចៀរជ័រនិងការប្រើប្រាស់ថ្នាំរំញោចនៅក្នុងឡូត៍ពិសោធន៍កូន។

### ៥.៤ ការស្រាវជ្រាវអំពីសរីរវិទ្យានិងអាជីវកម្ម

-ចំពោះការពិសោធន៍ $d_3$ ពូជ PB330 ផ្តល់ទិន្នផលជ័រខ្ពស់ជាងពូជនៅបច្ច័យ T2: S/2 d3 7d/d ET 2.5% Pa 4/$_y$ បើប្រៀបធៀបទៅនឹងពូជនៃបច្ច័យផ្សេងទៀត

-ចំពោះការពិសោធន៍ $d_4$ ពូជ RRIM712 ផ្តល់ទិន្នផលជ័រខ្ពស់ជាងពូជនៅបច្ច័យ T2: S/2 d4 7d/d ET 2.5% Pa 12/$_y$ បើប្រៀបធៀបទៅនឹងពូជនៃបច្ច័យផ្សេងទៀត។

### ៥.៥ ការស្រាវជ្រាវ ការដាំដុះ និងការពារ

-វាស់ទំហំដើមកូនកៅស៊ូចម្ការពិសោធន៍

-សហការជាមួយអ្នកបច្ចេកទេសពីសាកលវិទ្យាល័យ Nagoya ដើម្បីថែទាំ ជួសជុលឧបករណ៍ Sap flow $CO_2$ profile

-សហការជាមួយអ្នកបច្ចេកទេសពីសាកលវិទ្យាល័យ Kuyshu ដើម្បីស្រាវជ្រាវអំពី Leaf photosynthesis ។

### ៥.៦ ការងារនៅស្ថានីយអនុវត្ត

-បំប៉ោកូនកៅស៊ូនៅថ្នាលកូនបុក ១១ បានចំនួន ២៨.០០០កូន

-លាបកំបោរដើមកៅស៊ូឆ្នាំ២០១០ ដល់ឆ្នាំ២០១២។

### ៥.៧ ការងារក្នុងមន្ទីរពិសោធន៍យថាប្រភេទ

-ធ្វើតេស្តវិភាគសំណាកយថាប្រភេទចំនួន៨៩ ដើម្បីបញ្ជាក់គុណភាពការកែច្នៃរោងចក្រ

-ចុះបញ្ជិកាមន្ទីរពិសោធន៍យថាប្រភេទនៃក្រុមហ៊ុន ស៊ីហ្វ វីសស៍ (ខេមបូឌា) លីមីធីត ចម្ការកៅស៊ូស្នួល ដើម្បីទទួលបានលិខិតទទួលស្គាល់ជាផ្លូវការនិងសិទ្ធិប្រើប្រាស់ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជា

-ចុះបញ្ជិកាជាមួយមន្ទីរពិសោធន៍យោងសម្រាប់ផលិតផលកៅស៊ូដោយក្រុមការងារផលិតផលកៅស៊ូអាស៊ាន។

## ៦ ផ្នែករដ្ឋបាល

-ទទួលលិខិតពីក្រសួងនិងស្ថាប័ននានា សរុបចំនួន១.៤៣៦ច្បាប់ ទទួលពីអង្គភាពក្រោមឱវាទ សរុបចំនួន១.០៩៤ ច្បាប់ និងទទួលពីរាជធានី ខេត្ត សរុបចំនួន៣៤១ច្បាប់

-បញ្ជូនឯកសារនិងលិខិតទៅស្ថាប័នផ្សេងៗ អង្គភាពក្រោមឱវាទ និងរាជធានី ខេត្ត សរុបចំនួន១.៩៧៤ច្បាប់ ប្រកាស សេចក្តីសម្រេច និងសារាចរ សរុបចំនួន១១៣ច្បាប់ និងចម្លងចែកទៅអង្គភាពក្រោមឱវាទ សរុបចំនួន២២៥ច្បាប់

-ក្រៅពីនេះគឺមានការទទួលរៀបចំកិច្ចប្រជុំផ្ទៃក្នុងរបស់ក្រសួងនិងការទទួលភ្ញៀវជាតិ អន្តរជាតិ ការចូលរួមរៀបចំពិធីបុណ្យជាតិ អន្តរជាតិជាដើម ...។ល។

## ៧ ផ្នែកសវនកម្មផ្ទៃក្នុង

-ចុះធ្វើសវនកម្មតាមផែនការសកម្មភាពសវនកម្មប្រចាំឆ្នាំ២០១៣បានចំនួន៨អង្គភាព ក្នុងនោះមានមន្ទីរកសិកម្មខេត្តរតនគិរី មណ្ឌលគិរី កំពង់ចាម កំពត ព្រះសីហនុ ឧត្តរមានជ័យ ព្រះវិហារ និងវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា និងបានរាយការណ៍ជូនអាជ្ញាធរសវនកម្មជាតិជាបន្តបន្ទាប់និងទាន់ពេលវេលា។

## ៨ ផ្នែកវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា

-ទទួលគណៈប្រតិភូមកពីប្រទេសឡាវចំនួន១២នាក់ ដែលដឹកនាំដោយ Dr. Bounthong Buahom, អគ្គនាយករបស់ National Agriculture and Forestry Research Institute (NAFRI), Lao PDR

-ទទួលជួបនិងធ្វើបទបង្ហាញនូវលទ្ធផលការងារពិសោធន៍ស្រាវជ្រាវ និងពិភាក្សា ព្រមទាំងផ្តល់ប្រឹក្សាចំនួន១៣លើក ជាមួយគណៈប្រតិភូ ភ្ញៀវជាតិ និងអន្តរជាតិចំនួន៦២នាក់

-ធ្វើពិសោធន៍ចំនួន៣២ប្រភេទ នៅ១៩៥កន្លែង ក្នុងនោះមានពិសោធន៍បន្សាំពូជលើស្រែកសិករចំនួន៥៣កន្លែង

-ធ្វើអង្កេតបានចំនួន៥ប្រភេទ ដោយបានធ្វើសម្ភាសន៍កសិករចំនួន៦០០គ្រួសារ

-រៀបចំនិងបោះពុម្ពសៀវភៅស្មៅចង្រៃនៃដំណាំស្រូវនៅអាស៊ីចំនួន១.៥០០ច្បាប់ និងបានធ្វើការបែងចែកសៀវភៅឯកសារនានាចំនួន១.០២២ច្បាប់ និងព្រឹត្តិបត្រព័ត៌មានកសិករចំនួន២.៨០០ច្បាប់

-បន្តការអភិរក្សពូជដំណាំដែលមាននៅក្នុងធនាគារពូជ នៅក្នុងផ្ទះសំណាញ់ និងនៅក្នុងចម្ការចំនួន៣០ប្រភេទ ដែលក្នុងនោះមានស្រូវចំនួន៥.៩៧៧បញ្ជីក/សំណាក និងដំណាំផ្សេងៗចំនួន២៩ប្រភេទ រួមមាន៩០៣បញ្ជីក/សំណាក

-ការស្រាវជ្រាវរកព័ត៌មានបច្ចេកទេសកសិកម្មក្នុងគេហទំព័រ www.cardi.org.kh និង www.crkb.org.kh មានអ្នកចូលរួមសរុបចំនួន៤៧.៧១៥នាក់ គិតជាមធ្យមប្រមាណ ៥៣០នាក់ក្នុងមួយថ្ងៃ ក្នុងនោះប្រទេសកម្ពុជាចំនួន ៦៦% សហរដ្ឋអាមេរិកចំនួន១០% អូស្ត្រាលីចំនួន ៧% ជប៉ុនចំនួន៥% វៀតណាមចំនួន៤% និងប្រទេសផ្សេងៗទៀត(៨៦ប្រទេស) ចំនួន៨%

-បើកវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងសន្និបាតចំនួន៣វគ្គ ដែលមានអ្នកចូលរួមសរុបចំនួន៧២នាក់ ។

## ៩ សាលាជាតិកសិកម្មព្រែកលៀប

**៩.១ និស្សិតដែលកំពុងសិក្សានាឆ្នាំសិក្សា២០១២-២០១៣ សរុបមានចំនួន១.៥៩០នាក់(ស្រី៥០៩នាក់)ក្នុងនោះ៖**

• **និស្សិតអាហារូបករណ៍ចំនួន១.២០៦នាក់** ក្នុងនោះស្រី៤៣៨នាក់ ÷

-ថ្នាក់បរិញ្ញា *៩៦៣*នាក់ (ស្រី ៣៤៧នាក់ )សិក្សាលើមុខជំនាញវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រព្រៃឈើ វិទ្យាសាស្ត្រ និងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ សាកវប្បកម្ម សេដ្ឋកិច្ចនិងគ្រប់គ្រងកសិកម្ម កសិឧស្សាហកម្ម និងសុរិយោដី

-ថ្នាក់បរិញ្ញារង *២៤៣*នាក់ (ស្រី ៩១នាក់) សិក្សាលើមុខជំនាញក្សេត្រសាស្ត្រ រុក្ខកម្ម ផលិតកម្មនិងបសុព្យាបាល ផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ សាកវប្បកម្ម សេដ្ឋកិច្ចនិងគ្រប់គ្រងកសិកម្ម ជលផល កសិឧស្សាហកម្ម និងសុរិយោដី។

•និស្សិតបង់ថ្លៃចំនួន១៩៦នាក់ ក្នុងនោះស្រី២៧នាក់ ÷

-ថ្នាក់បរិញ្ញា *១៥៤*នាក់ (ស្រី ២៤នាក់ ) សិក្សាលើមុខជំនាញវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រព្រៃឈើ វិទ្យាសាស្ត្រ និងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ សេដ្ឋកិច្ចកសិកម្ម កសិឧស្សាហកម្ម និងសុរិយោដី

-ថ្នាក់បរិញ្ញារង*៤២*នាក់ (ស្រី ០៣នាក់) សិក្សាលើមុខជំនាញក្សេត្រសាស្ត្រ រុក្ខកម្ម ផលិតកម្មនិងបសុព្យាបាល និងផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ។

•និស្សិតបណ្តុះបណ្តាលបន្តថ្ងៃសៅរ៍-អាទិត្យចំនួន១៨៨នាក់ ក្នុងនោះ ស្រី៤៤នាក់ ÷

-ថ្នាក់បរិញ្ញា *១៤៨*នាក់ (ស្រី ៣៧នាក់) សិក្សាលើមុខជំនាញវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ និងសុរិយោដី

-ថ្នាក់បរិញ្ញារង *៤០*នាក់ (ស្រី ០៧នាក់) សិក្សាលើមុខជំនាញផលិតកម្មនិងបសុព្យាបាល ។

**៩.២ ការងារផលិតកម្មនិងស្រាវជ្រាវ**

-កសិដ្ឋានដំណាំលម្អបានដាំផ្កា ឈើពណ៌ ដូងតាំង និងពង្រីកពូជបន្ថែមសម្រាប់ការអនុវត្តនិងដាំលម្អក្នុងបរិវេណសាលាជាតិ បណ្តុះកូនក្លាន ស្លាកន្ទុយកំប្រុក

-បើកវគ្គបណ្តុះបណ្តាលស្តីពីការចិញ្ចឹមមាន់និងចិញ្ចឹមជ្រូក មានសិក្ខាកាមចូលរួមចំនួន១៤នាក់

-បើកវគ្គបណ្តុះបណ្តាលស្តីពីការផលិតមេផ្សិត បណ្តុះផ្សិត មានសិក្ខាកាមចូលរួមចំនួន២៩នាក់ ស្ត្រី០២នាក់។

## ១០ សាលាជាតិកសិកម្មកំពង់ចាម

**១០.១ និស្សិតដែលកំពុងសិក្សានាឆ្នាំសិក្សា២០១២-២០១៣ សរុបមានចំនួន១.៥៥៩នាក់(ស្រី៦០៨នាក់) ក្នុងនោះ ÷**

-និស្សិតអាហារូបករណ៍សរុប១.២៩៥នាក់(ស្រី៥៣៥នាក់)ក្នុងនោះថ្នាក់បរិញ្ញាវិទ្យាសាស្ត្រកសិកម្ម៩១៣នាក់(ស្រី៣១២នាក់) និងថ្នាក់បរិញ្ញារង៣៨២នាក់(ស្រី១៩៦នាក់) ដែលកំពុងសិក្សាមុខជំនាញក្សេត្រសាស្ត្រ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ

-និស្សិតសិក្សាបង់ថ្លៃ២៦៤នាក់ (ស្រី៧៣នាក់) ថ្នាក់បរិញ្ញាចំនួន២៥២នាក់(ស្រី៧៣នាក់) និងថ្នាក់បរិញ្ញារងចំនួន១២នាក់(ស្រី០នាក់) កំពុងសិក្សាមុខជំនាញក្សេត្រសាស្ត្រ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ និងសេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ ។

**១០.២ ការងារពិសោធន៍ស្រាវជ្រាវ**

-ធ្វើការពិសោធន៍ដំណាំសណ្តែកសៀង

-ធ្វើការពិសោធន៍លើប្រសិទ្ធភាពជីអាសូត ផូស្វ័រ ប៉ូតាស្យូម លើការលូតលាស់ដំណាំម្ទេសដៃនាង

-ពិសោធន៍តាមដានការលូតលាស់ជ្រូកមេក្នុងការចិញ្ចឹមតាមរយៈការប្រើប្រាស់ចំណីឧស្សាហកម្ម។

**១០.៣ ការងារស្រាវជ្រាវ ផ្សព្វផ្សាយ និងការផ្ទេរបច្ចេកវិជ្ជាកសិកម្ម**

-បន្តការងារស្រាវជ្រាវផលិតកម្មដំណាំស្រូវ ដែលបានឧបត្ថម្ភជំនួយពី ACIAR-CARF

-បន្តការងារស្រាវជ្រាវលើបសុវប្បកម្ម ដែលបានឧបត្ថម្ភជំនួយពី DEL-phe(UK)

-ធ្វើសិក្ខាសាលាស្តីពីការផ្តល់ចំណីគោតាមរយៈស្មៅចំណីនាំចូលនិងការប្រើប្រាស់កូនបន្លៃផ្តល់ទិន្នផលខ្ពស់ ដែលមានសិក្ខាកាម និស្សិត-គ្រូ និងកសិករចំនួន ១១៩នាក់

-ចុះផ្សព្វផ្សាយពីការធ្វើឥណទានស្រូវពូជ ជ្រូកពូជ និងចាក់វ៉ាក់សាំងការពារជំងឺសត្វគោ ក្របី នៅតាមមូលដ្ឋានឃុំ-ស្រុកក្នុងខេត្តកំពង់ចាម

-ផ្ដល់ពូជជ្រូកជូនដល់កសិករក្រីក្រនៅស្រុកត្រាំកក់ ខេត្តតាកែវ និងស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម បានចំនួន១៨គ្រួសារ

-ធ្វើការប្រជុំកសិករណែនាំពីការប្រើប្រាស់ថ្នាំពុលគីមី ជីគីមី និងជីសរីរាង្គនៅក្នុងមូលដ្ឋានស្រុកត្រាំកក់ ខេត្តតាកែវ និងស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម

-ធ្វើការបណ្ដុះបណ្ដាលវគ្គខ្លីជូនកសិករលើបច្ចេកទេសដាំដំណាំផ្សិតបានចំនួន ៨នាក់ និងការដាំដំណាំស្រូវផ្ដល់ទិន្នផលខ្ពស់បានចំនួន ២៥គ្រួសារ នៅក្នុងឃុំដងក្ដា ឃុំខ្ពបតាងួន ឃុំពាមកោះស្នា និងឃុំសូភាស ស្រុកស្ទឹងត្រង់។

## ១១ សាកលវិទ្យាល័យភូមិន្ទកសិកម្ម

-និស្សិតដែលកំពុងសិក្សាមានចំនួនសរុប៩.៦៩៧នាក់ (ស្រី១.២៣៣នាក់) ចែកចេញជា១០មហាវិទ្យាល័យគឺ មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រព្រៃឈើ វិទ្យាសាស្ត្រជលផល វិស្វកម្មកសិកម្ម សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ កសិឧស្សាហកម្ម រៀបចំដែនដីនិងរដ្ឋបាលដីធ្លី វិទ្យាសាស្ត្រកៅស៊ូ ដែលសិក្សាតាមកម្មវិធីថ្នាក់បរិញ្ញាវិទ្យាសាស្ត្រនិងសាលាក្រោយឧត្តម បណ្ដុះបណ្ដាលលើកម្មវិធីបរិញ្ញារង បរិញ្ញាបត្រ បរិញ្ញាជាន់ខ្ពស់ និងថ្នាក់បណ្ឌិតវិទ្យាសាស្ត្រ

-បើកវគ្គបណ្ដុះបណ្ដាលក្នុងប្រទេសចំនួន២៥លើក និងក្រៅប្រទេសចំនួន២១លើក និងសិក្ខាសាលាក្នុងប្រទេសចំនួន២៤លើក និងក្រៅប្រទេសចំនួន២២លើក

-បញ្ជូននិស្សិតទៅចូលរួមវគ្គបណ្ដុះបណ្ដាលនិងកម្មសិក្សានៅក្រៅប្រទេសចំនួន១២នាក់ និងមន្ត្រីរាជការចំនួន ១២នាក់

-បញ្ជូននិស្សិតទៅធ្វើកម្មសិក្សានៅប្រទេសអ៊ីស្រាអែលចំនួន៣០នាក់

-អនុវត្តគម្រោងស្រាវជ្រាវនិងអភិវឌ្ឍន៍ចំនួន២៣គម្រោង គម្រោងទាំងនោះមានគម្រោងស្រាវជ្រាវនិងអភិវឌ្ឍន៍ចម្រុះជំនាញផ្នែកវិទ្យាសាស្ត្រកសិកម្ម ផ្នែកវិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ ផ្នែកវិទ្យាសាស្ត្រព្រៃឈើ ផ្នែកវិទ្យាសាស្ត្រជលផល ផ្នែកស្រាវជ្រាវ-ផ្សព្វផ្សាយ ផ្នែករៀបចំដែនដីនិងរដ្ឋបាលដីធ្លី

-ធ្វើការផ្លាស់ប្ដូរបទពិសោធន៍ពីគ្នាទៅវិញទៅមករវាងសាស្ត្រាចារ្យនិងនិស្សិត ព្រមទាំងខិតខំពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិយ៉ាងទូលំទូលាយ ក្នុងទិសដៅពង្រឹងគុណភាពអប់រំឱ្យបានល្អប្រសើរដើម្បីឱ្យមានលក្ខណៈប្រកួតប្រជែង

-បញ្ជូននិស្សិតចុះជួយវាស់វែងដីធ្លីជូនប្រជាជន ដើម្បីចូលរួមអនុវត្តនយោបាយចាស់សកម្មភាពថ្មីលើវិស័យដីធ្លីរបស់រាជរដ្ឋាភិបាលចំនួន៤២៩នាក់ មកពីមហាវិទ្យាល័យរៀបចំដែនដីនិងរដ្ឋបាលដីធ្លី វិទ្យាសាស្ត្រកសិកម្ម និងសេដ្ឋកិច្ចកសិកម្មនិងជនបទ។

## III-សេចក្តីសន្និដ្ឋាននិងវាយតម្លៃ

ការងារបង្កបង្កើនផលស្រូវរដូវប្រាំងសម្រេចបាន ១៣៥,០៤%នៃផែនការ លើសឆ្នាំមុនបើប្រៀបធៀបរយៈពេលដូចគ្នា ជាមួយនឹងការប្រមូលផលសម្រេចបាន ៨៨,៩៣%នៃផ្ទៃដីអនុវត្តនិងឈានជិតដល់បញ្ចប់។ ទន្ទឹមនឹងនោះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជំរុញការងារបង្កបង្កើនផល ព្រមទាំងណែនាំប្រជាកសិករឱ្យបង្កើនការយកចិត្តទុកដាក់ថែទាំលើដំណាំនិងប្រើប្រាស់ទឹកឱ្យបានសមស្រប ជាពិសេសអប់រំណែនាំកសិករឱ្យយកចិត្តទុកដាក់ជំរុញការងារមុននិងក្រោយពេលប្រមូលផល រៀបចំរក្សាទុកដាក់ផលស្រូវឱ្យបានល្អ ដើម្បីធានាសន្តិសុខស្បៀងក្នុងគ្រួសារនិងការលែទុកពូជ។ ក្រសួងនៅតែចាត់វិធានការនិងពិនិត្យតាមដានបន្តទៀតដើម្បីទប់ស្កាត់ការរាលដាលជំងឺផ្ដាសាយបក្សីនិងជំងឺឆ្លងសត្វពីតំបន់មួយទៅតំបន់មួយ។



Th

IV- **និសដៅ**

-ជំរុញការងារប្រមូលផលស្រូវរដូវប្រាំងឆ្នាំ២០១២-២០១៣

-ពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើនិងបទបញ្ជារបស់រាជរដ្ឋាភិបាលលេខ ០១ និង ០២

-បន្តជំរុញកំណត់ព្រំប្រទល់ដែនព្រៃឈើ ធ្វើចំណាត់ថ្នាក់ និងចុះបញ្ជិកាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ឱ្យមានការចូលរួមប្រកបដោយប្រសិទ្ធភាពពីគ្រប់ភាគីពាក់ព័ន្ធ ហើយត្រូវសម្រេចឱ្យបានប្រវែង ១.០០០គីឡូម៉ែត្រ

-ជំរុញដាក់ឱ្យដេញថ្លៃជាសាធារណៈចំពោះឈើដែលបានរឹបអូសតាមសាលក្រមរបស់តុលាការនិងតាមការពិន័យអន្តរការណ៍

-បន្តតាមដានត្រួតពិនិត្យនិងវាយតម្លៃប្រសិទ្ធភាពនៃកម្មវិធី ដោយលើកកម្ពស់កម្រិតជីវភាពប្រជាជននៅតាមតំបន់ជនបទ ស្ថិរភាពធនធានព្រៃឈើ និងការពង្រីកសហគមន៍ព្រៃឈើឱ្យបានកាន់តែទូលំទូលាយ ដោយរៀបចំបែបបទទទួលស្គាល់ជាផ្លូវការ និងអភិវឌ្ឍសហគមន៍ព្រៃឈើថ្មីចំនួន ១០០កន្លែងបន្ថែមទៀត

-បន្តសហការជាមួយដៃគូនានា អនុវត្តគម្រោងការបណ្តុះបណ្តាល ដើម្បីពង្រឹងសមត្ថភាពរដ្ឋបាលព្រៃឈើនិងភាគីពាក់ព័ន្ធ

-បន្តលើកកម្ពស់គុណភាពនិងប្រសិទ្ធភាពនៃការអប់រំផ្សព្វផ្សាយពីសារប្រយោជន៍ស្តីពីព្រៃឈើ តាមរយៈការផលិតសម្ភារនិងឯកសារបច្ចេកទេស

-បន្តបង្កើនសកម្មភាពសិក្សាស្រាវជ្រាវនិងអភិវឌ្ឍព្រៃឈើសត្វព្រៃតាមរយៈការធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រនិងផែនការសកម្មភាពស្រាវជ្រាវ

-កំណត់តំបន់ព្រៃឈើរេចរឹលឱ្យបានច្បាស់ ដើម្បីធ្វើការស្តារព្រៃឈើឡើងវិញឱ្យក្លាយជាតំបន់ព្រៃឈើមានតម្លៃពាណិជ្ជកម្មដោយធ្វើការដាំដុះប្រភេទឈើប្រណិតមានតម្លៃនិងថែរក្សាការពារចម្ការព្រៃពូជ ព្រមជាមួយការប្រមូលពូជឈើ

-បន្តចូលរួមជាមួយគណៈកម្មការអន្តរក្រសួងចុះដេញថ្លៃផល អនុផលព្រៃឈើដែលរឹបអូសដោយសាលក្រម ដីកាសម្រេច ពិន័យអន្តរការណ៍ និងឈើអញ្ញាតជន(ឈើគ្មានម្ចាស់)នៅទូទាំងប្រទេស

-បន្តបង្កើនកិច្ចសហប្រតិបត្តិការល្អជាមួយស្ថាប័ន សមត្ថកិច្ចជំនាញ និងភាគីពាក់ព័ន្ធនានា ជាពិសេសអ្នកសារព័ត៌មាននិងព្រះរាជអាជ្ញាឱ្យជួយគាំទ្រដល់ការងារពង្រឹងការអនុវត្តច្បាប់ប្រកបដោយតម្លាភាពនិងប្រសិទ្ធភាពខ្ពស់

-រៀបចំសេចក្តីណែនាំនិងដាក់ឱ្យប្រើប្រាស់សៀវភៅកត់ត្រាឈើចេញចូលតាមរោងសិប្បកម្មផល អនុផលព្រៃឈើ

-បន្តត្រួតពិនិត្យបទល្មើសនេសាទទឹកសាបនៅរាជធានី ខេត្តឱ្យកាន់តែមានប្រសិទ្ធភាព

-បន្តការតាមដានសកម្មភាពអាជីវកម្មនេសាទសមុទ្រ

-បន្តការងារផ្សព្វផ្សាយការអភិវឌ្ឍន៍វិស័យវារីវប្បកម្មនិងការគ្រប់គ្រងធនធានជលផល

-បន្តការងារស្រាវជ្រាវដើម្បីកំណត់អត្តសញ្ញាណកូនត្រីទៅតាមប្រភេទនីមួយៗនៅតាមដងទន្លេមេគង្គ

-រៀបចំសេចក្តីព្រាងប្រកាសស្តីពី "ការគ្រប់គ្រងកសិដ្ឋានចិញ្ចឹមសត្វ"

-រៀបចំគម្រោងបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមសត្វនៅតាមបណ្តារាជធានី ខេត្ត

-ត្រៀមលក្ខណៈចុះអនុវត្តវិធានបសុពេទ្យនៅកន្លែងផ្ទុះជំងឺនិងកន្លែងដែលមានការឆ្លងរាលដាលជំងឺផ្តាសាយបក្សីនិងជំងឺផ្តាសាយ (A) H1N1

-ពង្រឹងទប់ស្កាត់ចរាចរណ៍សត្វនិងផលិតផលសត្វតាមទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែនទ្វេភាគី ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារកំពង់ផែសមុទ្រ

-ចុះផ្សព្វផ្សាយអំពីលក្ខណៈនិងសញ្ញាណជំងឺជ្រូកត្រចៀកខៀវ ប៉េស្ត និងវិធានការទប់ស្កាត់នៅតាមរាជធានី ខេត្ត

-ចុះតាមដានសកម្មភាពចាក់ថ្នាំការពារជំងឺគោ ក្របី និងពិនិត្យស្ថានភាពជំងឺសត្វនៅតាមរាជធានី ខេត្ត

-ចូលរួមធ្វើតេស្តអន្តរមន្ទីរពិសោធន៍លើកទី ១០៥ ជាមួយ IRA

-អង្កេតទូទៅស្ថានភាពជំងឺគ្រប់ឡូត៍ពិសោធន៍កូនកៅស៊ូនិងត្រួតពិនិត្យជំងឺកៅស៊ូ

-ចុះពិនិត្យនៅតាមបណ្តាមន្ទីរពិសោធន៍យថាប្រភេទនិងរោងចក្រកែច្នៃកៅស៊ូ

-ពង្រឹងការងារបញ្ជិកាគណនេយ្យនៅតាមបណ្តាអង្គភាពក្រោមឱវាទនិងបណ្តាមន្ទីរកសិកម្មរាជធានី ខេត្ត

-បន្តចុះពិនិត្យផ្ទាល់ដល់ទីវាលរបស់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដើម្បីមានមូលដ្ឋានរាយការណ៍ឱ្យបានច្បាស់លាស់

-បន្តយកចិត្តទុកដាក់លើការសិក្សាស្រាវជ្រាវនិងកសាងគោលការណ៍លិខិតបទដ្ឋានណែនាំជាសារាចរ សេចក្តីណែនាំអំពីការងារគ្រប់គ្រងមន្ត្រីរាជការ និងរៀបចំបែបបទការអនុវត្តជាក់ស្តែងក្នុងការគ្រប់គ្រងធនធានមនុស្សឱ្យល្អប្រសើរតាមប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យា ដោយចងក្រងតាមកម្រិតសញ្ញាប័ត្រ មុខជំនាញ និងតាមមុខតំណែង

-ពង្រឹងការគ្រប់គ្រងនិងអភិវឌ្ឍធនធានមនុស្សឱ្យបានសមស្របទៅតាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការនៃព្រះរាជាណាចក្រកម្ពុជា

-ពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការជាតិ អន្តរជាតិក្នុងវិស័យកសិកម្មឱ្យបានទូលំទូលាយជាមួយគ្រប់ដៃគូពាក់ព័ន្ធទាំងអស់

-បន្តរៀបចំលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ស្តីពីព្រៃឈើ ស្តីពីជលផល ច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំនិងសិទ្ធិអ្នកបង្កាត់ពូជដំណាំ និងច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម ដើម្បីធានាដល់ប្រសិទ្ធភាពពេញលេញក្នុងការអនុវត្ត

-រៀបចំច្បាប់ផ្សេងៗទៀតដូចជា ច្បាប់ស្តីពីការគ្រប់គ្រងនិងប្រើប្រាស់ជីកសិកម្ម ច្បាប់ស្តីពីកៅស៊ូ ច្បាប់ស្តីពីសុខភាពសត្វនិងផលិតកម្មសត្វ ។ល។

-បន្តរៀបចំលិខិតបទដ្ឋានគតិយុត្តនិងអត្ថបទក្រោមច្បាប់តាមអនុវិស័យ ដើម្បីដំណើរការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទឱ្យស្របតាមខ្លឹមសារអនុក្រឹត្យលេខ ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ៕

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ២០១៣

**រដ្ឋមន្ត្រី**

ចន្ទ សារុន